កុមាររៀន
កុមារចេះ
ក ១ ២៣

# ចន្ទ្រានិងចន្ត្រា



**កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា**

រឿង ៖ **ចន្ទ្រានិងចន្ត្រា**

និពន្ធដោយ ៖ **លោក ជូ ជីនិត**

កែសម្រួលដោយ ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**

វិចិត្ររូបភាពដោយ ៖ **លោក សេង វិសាល**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read

www.LetsReadAsia.org

ចន្ទ្រានិងចន្ត្រាកំពុងលេងបាយឡុកបាយឡ
ជាមួយគ្នានៅមុខផ្ទះ។



ចន្ត្រាធ្វើជាស្លៀកពាក់ខោអាវកន្ត្រកកន្ត្រាក សក់កន្ទ្រើងកន្ទ្រើង។ ចំណែកឯចន្ទ្រា ធ្វើជាស្លៀកពាក់ខោអាវហ៊ឺហា។





កំពុងលេងសប្បាយ ស្រាប់តែ...«ចន្ទ្រា ចន្ទ្រា! ទៅរកបេះផ្លែអង្រ្កង ឱ្យម៉ែបន្តិចមកកូន»។

ឮដូច្នេះ ចន្ទ្រាស្ទុះរឹងទៅកន្ត្រាក់យក
កញ្ច្រែងក្បែរចង្ក្រាន។ ចន្ត្រាក៏លីកកន្ត្រង
បេះផ្លែឈើទៅជាមួយចន្ទ្រាដែរ។



ចន្ទ្រាដើរយ៉ាងរហ័សទៅរកដើមអង្គ្រង។
ដើមអង្គ្រងនោះនៅជិតដើមអង្ក្រេមអង្ក្រម។







ចន្ទ្រាក៏លោតកន្ត្រោងបេះផ្លែអង្គ្រង។
ចន្ទ្រាក៏លើកកន្ត្រងបេះផ្លែអង្គ្រង។

ស្រាប់តែ ចន្ទ្រាឃើញកូនចាប
ចង្ក្រង់មួយធ្លាក់ពីសំបុក។





កូនចាបចង្ក្រង់នោះ ត្រូវអង្ក្រងខាំក្រោម
ដើមអង្ក្រមអង្ក្រម។ ចន្ទ្រានិងចន្ត្រានាំគ្នា
ជួយសង្គ្រោះកូនចាបចង្ក្រង់ពីហ្វូងអង្ក្រង។



ចន្ទ្រាបម្រុងនឹងយកកូនចាបចង្រ្កង់ដាក់ក្នុង
កញ្ច្រែងយកទៅផ្ទះ។ ស្រាប់តែ មេអង្រ្កងនាំគ្នា
សង្គ្រុបខាំចន្ទ្រា។ ហ្វូងអង្រ្កងគិតថា ចន្ទ្រានិងចន្ត្រា
ចង់មករុករានទន្ទ្រានសំបុករបស់វា។



ចន្ទ្រាភ្ញាក់នឹងអង្ក្រងខាំ ក៏របូតកញ្ច្រែងធ្លាក់ពីដៃ។
ចន្ទ្រាស្រែក ៖ «អូយ! អង្ក្រងខាំខ្ញុំហើយ»។



ចន្ត្រាក៏ស្ទុះរត់វឹងទៅជួយចន្ទ្រា។
ហ្វូងអង្ក្រងនាំគ្នាសង្គ្រុបខាំ
ទាំងចន្ទ្រានិងចន្ត្រា។



ចន្ទ្រានិងចន្ត្រាលោតទន្ត្រំដីក្រោមដើមអង្ក្រង។



រំពេចនោះ ចន្រ្ទានឹកឃើញរឿងមួយ។
ចន្រ្ទាមើលទៅចន្រ្ទាទាំងទឹកមុខងឿងឆ្ងល់។



ចន្ទ្រាចាំពាក្យម៉ែប្រាប់ថា «អង្រ្កងខ្លាចផេះចង្ក្រាន»។ ចន្ទ្រាស្រែកថា «យើងត្រូវការផេះចង្ក្រានដើម្បីបង្ក្រាបអង្រ្កង»។ ចន្ត្រាក៏ស្ទុះភ្លែតទៅផ្ទះដើម្បីកើបផេះចង្ក្រានបង្ក្រាបអង្រ្កង។



ចន្ត្រាក៏ជះផេះបង្ក្រាបហ្វូងអង្ក្រង។ ហ្វូងអង្ក្រង ត្រូវផេះចង្ក្រាន រអិលអន្ត្រាក់អន្ទ្រើកធ្លាក់ពី លើដើមអង្គ្រង។ ចន្ទ្រានិងចន្ត្រា ស្រែកហ៊ោ កញ្ជ្រៀវសប្បាយរីករាយ។



ស្រាប់តែ ចន្ទ្រានិងចន្ត្រា លាន់មាត់ដំណាលគ្នាថា «ឯណាកូនចាបចង្រ្កង់?» ។ ចន្ទ្រានិងចន្ត្រា ក៏នាំគ្នាតាមរកកូនចាបចង្រ្កង់។



កូនចាបចង្រ្កង់សំងំកន្រ្តោនៗក្នុងគុម្ពទន្រ្ទាន
ខែត្រកៀ្សរនោះ ។ ចន្រ្ទានិងចន្រ្តាក៏សង្រ្គុបចាប់
បានកូនចាបចង្រ្កង់។ កូនចាបចង្រ្កង់កញ្រ្ជោល
ស្ទុះកន្រ្តោង ព្រោះភ័យខ្លាចចន្រ្ទានិងចន្រ្តា។





ចន្ទ្រានិងចន្ត្រាជួយថែទាំកូនចាប
ចង្ក្រង់ឱ្យបាត់ភិតភ័យ។ ចន្ទ្រានិង
ចន្ត្រាបញ្ចុកចំណីកូនចាបចង្ក្រង់។



កូនចាបចង្រ្កង់ច្រៀងកញ្ជ្រៀវ
លោតកញ្ជ្រោលអន្ទ្រើតៗ។
ចន្ត្រាក៏ចាប់កូនចាបចង្រ្កង់
ដាក់ក្នុងសំបុកវិញ។



ចន្ទ្រានិងចន្ទ្រា ប្រមូលផ្លែអង្គ្រងដាក់កញ្ជ្រែង។ ចន្ទ្រានិងចន្ទ្រាលាកូនចាបចង្រ្កង់ត្រឡប់ទៅផ្ទះវិញ។



# ពន្យល់ពាក្យ

១. កន្ត្រកកន្ត្រាក : រយីករយាក មិនសូវស្អាត

២. លោតទន្ទ្រំ : លោតនៅលើដីខ្លាំងៗ

៣. កន្ត្រាក់ : ទាញយកដោយប្រញាប់

៤. កន្ត្រាង : លោតបេះ

៥. បញ្ច្រុក : ច្រកដោយបង្ខំ



# សំណួរ

១. តើចន្ទ្រានិងចន្ត្រាកំពុងលេងអ្វី? នៅឯណា?

២. តើចន្ទ្រានិងចន្ត្រាបានជួបកូនចាបចង្ក្រង់នៅឯណា?

៣. តើកូនគិតថា ហេតុអ្វីបានជាចន្ទ្រានិងចន្ត្រា ជួយសង្គ្រោះកូនចាបចង្ក្រង់?

៤. ចុះកូនវិញ តើកូនធ្លាប់ជួយសង្គ្រោះសត្វអ្វី ឬនរណាម្នាក់ដែរឬទេ? តើកូនសង្គ្រោះគេដោយរបៀបណា?





IPEA, Kg.Chhnang, 789 copies, SSK, Oct. 2022

បន្ទាប់ពីរៀនចប់មេរៀនទី៣១ រំឭក **«ព្យាង្គតម្រួត ន្ត្រ ន្ទ្រ»** នៃសៀវភៅថ្នាក់ទី២ សិស្សនឹងអាចអានសៀវភៅរឿងនេះបានដោយខ្លួនឯង ដោយពុំចាំបាច់មានអ្នកជួយឡើយ។

ទោះជាយ៉ាងណា សិស្សថ្នាក់ទី១ ក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើលនិងរៀបរាប់អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះ ហើយអានពាក្យនិងតួអក្សរដែលពួកគេស្គាល់។

សូមចងចាំថា នៅពេលសិស្សចាប់ផ្តើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែប្រសើរសម្រាប់ពួកគេ!



កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

9 789924 560418
បោះពុម្ពឆ្នាំ២០២២